**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៩៥ ០១៤ ២២៣ ធ.ជ.ក

# សេចក្តីជូនដំណឹង
## ស្តីពី
## ការតម្លើងអត្រាការប្រាក់ និងការទទួលទិញត្រឡប់វិញ នូវមូលបត្រអាចជួញដូរបាន មុនកាលវសាន

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជូនដំណឹងដល់បណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជាជ្រាបថា ក្នុងគោលបំណងជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ បង្កលក្ខណៈងាយស្រួលដល់ការជួញដូរមូលបត្រអាចជួញដូរបាន(NCD)នៅក្នុងទីផ្សារទី២ ព្រមទាំងផ្តល់ជម្រើសដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការគ្រប់គ្រងនិងវិនិយោគសន្ទនីយភាពសល់ទំនេរ ធនាគារជាតិនៃកម្ពុជាសម្រេចៈ

១- តម្លើងអត្រាការប្រាក់ចំនួន ៥០% នៃអត្រាការប្រាក់ដែលបានអនុវត្តកន្លងមក ចំពោះ NCD ចារឹកជាប្រាក់រៀលនិងជាដុល្លារអាមេរិក។

២- ទទួលទិញ NCD ត្រឡប់វិញមុនកាលវសានតាមថ្លៃប្រកួតប្រជែង (Competitive Price) ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ក្នុងករណីដែលម្ចាស់ NCD ខ្វះសន្ទនីយភាពបណ្តោះអាសន្ន ដោយផ្អែកលើមូលហេតុច្បាស់លាស់ ។

៣- អនុញ្ញាតឲ្យម្ចាស់ NCD បញ្ចូលព័ត៌មានពាក់ព័ន្ធនឹង NCD ដែលចង់លក់ ឬ ចង់ទិញ ដូចជា ថ្លៃមូលបត្រ តម្លៃនាមចារឹក កាលអវសាន និងទូរស័ព្ទទំនាក់ទំនងជាដើម ក្នុងប្រព័ន្ធ Online Trading Platform នៃគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជា ។

ប្រតិបត្តិការពាក់ព័ន្ធនឹងការសុំជាវ ការផ្ទេរកម្មសិទ្ធិ និងការទិញ NCD ត្រឡប់វិញ ត្រូវអនុវត្តតាមគំរូដែលមានស្រាប់របស់ធនាគារជាតិនៃកម្ពុជា ។ គ្រឹះស្ថានធនាគារដែលមានបំណងចង់បានព័ត៌មានលម្អិតពាក់ព័ន្ធនឹង NCD សូមទាក់ទងមកនាយកដ្ឋានប្រតិបត្តិការធនាគារជាតិនៃកម្ពុជា រៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ឬតាមទូរស័ព្ទលេខ: 023 724 963 ឬតាម E-mail: chhin.dina@nbc.org.kh

សេចក្តីជូនដំណឹងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោក/លោកស្រី នាយក/នាយិកាជ្រាបជាព័ត៌មាន ។

ភ្នំពេញ, ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤
**អគ្គនាយកបច្ចេកទេស**

**ជា សិរី**

**កន្លែងទទួល:**
- គ្រប់អគ្គនាយកដ្ឋាន "ដើម្បីជូនជ្រាប"
- នាយកដ្ឋានក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលពាក់ព័ន្ធ
- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ "ដើម្បីជ្រាបនិងសហការអនុវត្ត"

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧